# យើងខ្ញុំនៅទីនេះចាំជួយលោកអ្នក

## ជម្រាបសួរ! យើងខ្ញុំជាស្ថាប័នទឹកភ្លើង។

តាមពិត! នេះមិនមែនជារបៀបដែលយើងខ្ញុំចង់ណែនាំខ្លួនយើងខ្ញុំជាថ្មីនោះទេ...

នាយកដ្ឋានរដ្ឋាករទឹក និងនាយកដ្ឋានហ្គាសក្រុងឡុងប៊ិចពីមុន ឥឡូវនេះសហការគ្នាបង្កើតបានជាស្ថាប័នទឹកភ្លើងក្រុងឡុងប៊ិច។

យើងខ្ញុំនៅតែជាអ្នកអាជីពច្បាស់លាស់ដូចមុន ដែលប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការផ្តល់សេវាល្អពិសេសផ្នែកទឹកស្អាត ហ្គាស និង ទឹកស្អុយ សម្រាប់ពលរដ្ឋ និងអាជីវកម្ម។ ស្ថាប័នទឹកភ្លើងក្រុងឡុងប៊ិច មានគោលបំណងបន្តផ្តល់សេវាគួរជាទីទុកចិត្ត ដែលលោកអ្នករំពឹងថាបាន ថែមទាំងបម្រើ និងផ្តល់អត្ថប្រយោជន៍បន្ថែមដល់សហគមន៍យើង។

**សារសំខាន់អំពីវិក្កយបត្រហ្គាសរបស់លោកអ្នក**

ជាអកុសល យើងខ្ញុំត្រូវចាប់ផ្តើមឆ្នាំថ្មីនេះ ដោយមានដំណឹងអាក្រក់ខ្លះ អំពីថ្លៃហ្គាសធម្មជាតិ។ ដោយសារតែថ្លៃហ្គាសធម្មជាតិនៅលើពិភពលោក មានការកើនឡើងខ្លាំង និងអាកាសធាតុត្រជាក់ជាងធម្មតា តម្លៃទីផ្សារនៃហ្គាស បានកើនឡើងគុណនឹងបីក្នុងរយៈពេលមួយខែចុងក្រោយនេះ សម្រាប់តំបនរដ្ឋកាលីហ្វ័រញ៉ាប៉ែកខាងត្បូង។

លោកអ្នកឃើញវិក្កយបត្រហ្គាសធម្មជាតិដែលបានឡើងខ្ពស់ជាងមុនរួចស្រេចទៅហើយ ពីខែធ្នូ។ វិក្កយបត្រសម្រាប់ខែមករា ក៏នឹងរឹតតែខ្ពស់ជាងនេះទៅទៀត។ អតិថិជនមួយគ្រួសារមធ្យម នឹងឃើញការកើនឡើងក្នុងវិក្កយបត្រក្នុងកម្រិត ២០០ដុល្លារ ឬច្រើនជាងនេះ។

**តើយើងខ្ញុំធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហានេះ?**

ក្នុងនាមជាស្ថាប័នទឹកភ្លើងរបស់ក្រុងឡុងប៊ិច យើងខ្ញុំកំពុងពិនិត្យមើលយុទ្ធសាស្ត្រ ក្នុងការជាវហ្គាសធម្មជាតិនាពេលបច្ចុប្បន្ន ដើម្បីរកមើលមធ្យោបាយបន្ថែម ក្នុងការផ្តល់ស្ថិរភាពតម្លៃហ្គាសឲ្យបានល្អ និងការពារអតិថិជនទៅថ្ងៃអនាគត។ យើងខ្ញុំកំពុង៖

- ប្រើឲ្យអស់ពលទ្ធភាពនៃហ្គាសដែលយើងស្តុកទុក ដែលមានតម្លៃថោកជាងនេះ
- រិះរកការចរចាជាមួយក្រុមហ៊ុនម៉ៅការផ្គត់ផ្គង់ហ្គាសក្នុងមូលដ្ឋានរបស់យើង
- បញ្ចូលទឹកប្រាក់ ១.៣លានដុល្លារទៅក្នុងប្រាក់បម្រុង ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់អតិថិជន

យើងខ្ញុំក៏ផ្តល់ជំនួយក្នុងផែនការទូទាត់ប្រាក់តាមដំណាក់កាលដែលមានរយៈពេលកាន់តែវែង កម្រិតនៃផែនការទូទាត់ប្រាក់តាមដំណាក់កាល ការទូទាត់សងវិញសម្រាប់សម្ភារៈ ការបញ្ចុះតម្លៃសម្រាប់អ្នកមានប្រាក់ចំណូលទាប សម្រាប់អតិថិជនដែលបំពេញគ្រប់លក្ខខណ្ឌ និងកម្មវិធីជំនួយអតិថិជនផ្សេងៗទៀត

**តើយើងគួរធ្វើយ៉ាងដូចម្តេច?**

យើងខ្ញុំដឹងថាអត្រាថ្លៃទឹកភ្លើងឡើងខ្ពស់ អាចជាបន្ទុកដ៏ធ្ងន់សម្បើមមួយ ជាពិសេសចំពេលដែលតម្លៃអតិផរណាកំពុងកើតមាននៅគ្រប់ទិដ្ឋភាពនៃជីវភាពប្រចាំថ្ងៃរបស់យើងក្នុងពេលនេះ។ យើងខ្ញុំនៅទីនេះដើម្បីជួយ និងរួមគ្នាដោះស្រាយបញ្ហា។

លោកអ្នកអាចជួយចាត់ការតាមលទ្ធភាព ដើម្បីបន្ថយតម្លៃក្នុងវិក្កយបត្រលោកអ្នកសម្រាប់ខែនេះផងដែរ។

- សូមបើកម៉ាស៊ីនកំដៅត្រឹម ៦៨ដឺក្រេ ឬទាបជាងនេះ។
- សូមបោកសម្លៀកបំពាក់ ដោយទឹកត្រជាក់
- សូមកាត់បន្ថយម៉ោងងូតទឹកក្តៅ
- សូមធ្វើឲ្យផ្ទះរបស់លោកអ្នកក្តៅ ដោយពន្លឺព្រះអាទិត្យពីធម្មជាតិ នៅពេលថ្ងៃ
- សូមរកភួយក្រាស់ៗមកដណ្តប់ ពាក់ស្រោមជើង និងអាវរងារ

**កំពុងជួបការលំបាកក្នុងការបង់ប្រាក់ឬ? កុំបារម្ភ**

សូមទូរស័ព្ទមកលេខនេះ៖ (562) 570-5700 ដើម្បីរៀបចំផែនការបង់ប្រាក់តាមដំណាក់កាល ដែលសមស្របសម្រាប់លោកអ្នក។
សូមស្វែងរកព័ត៌មានបន្ថែមនៅគេហទំព័រនេះ៖ longbeach.gov/energyresources